NGO-CEDAW

The Cambodian Committee of Women (CAMBOW)

CMN

Gender and Development Network

LICADHO

Sunshine CAMBODIA

# សេចក្តីប្រកាសព័ត៌មាន- ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០១៥

NGO-CEDAW និងបណ្តាញអង្គការក្រៅរដ្ឋាភិបាលកម្ពុជាក្នុងស្រុកមួយចំនួនដែលកំពុងតែធ្វើការងារលើកកម្ពស់សិទ្ធិស្ត្រី សូមស្នើដោយទទូចទៅរាជរដ្ឋាភិបាលកម្ពុជា សូមលោកមេត្តាពង្រឹង និងធ្វើវិសោធន៍កម្មលើច្បាប់ជាតិទាំងឡាយណា ដែលប៉ះពាល់ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារអោយអនុលោមតាមអនុសញ្ញាស៊ីដរ ។

យើងខ្ញុំសូមអំពាវនាវដល់អាជ្ញាធរមូលដ្ឋានទាំងអស់ សូមលោកមេត្តាការពារជនរងគ្រោះគ្រប់រូប បើទោះជាការរងគ្រោះដោយអំពើហិង្សានោះបន្សល់ទុកនៅរបួសស្នាម ឬបង្កឲ្យមានផលប៉ះពាល់ដល់ផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចក៏ដោយ។

យើងខ្ញុំទាំងអស់គ្នា ក៏សូមអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប មេត្តារាយការណ៍ពីការកើតឡើងនៃការរំលោភបំពានទាំងឡាយទៅអាជ្ញាធរមូលដ្ឋាន ពីព្រោះការរំលោភបំពានផ្តើមចេញពីការប្រព្រឹត្តតិចតួចហើយក៏បង្ករជាការប្រព្រឹត្តដែលធ្ងន់ធ្ងរឡើងៗ នឹងដែលអាចបណ្តាលឲ្យមានការបាត់បង់អាយុជីវិតមនុស្សផង។ ការដែលបណ្តោយឲ្យជនល្មើសរួចខ្លួនពីការដាក់ទោសទណ្ឌ មានន័យថាជាការបង្រៀនក្មេងៗឲ្យយល់ថាអំពើរំលោភបំពានគឺជារឿងធម្មតា និងអាចទទួលយកបាន។ ចាប់ពីពេលនេះទៅយើងទាំងអស់គ្នាត្រូវលុបបំបាត់ទំលាប់ទាំងនេះចោល ។

មកដល់ពេលនេះគឺ មានរយៈពេល ១០ឆ្នាំហើយ បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាបានដាក់អោយប្រើប្រាស់ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។ យើងទាំងអស់គ្នាឃើញយ៉ាងច្បាស់ថា ការអនុវត្តច្បាប់នៅមានកម្រិត និងនៅមិនទាន់មានប្រសិទ្ធិភាពនៅឡើយ ។ មានប្រជាពលរដ្ឋជាច្រើន រួមទាំងអាជ្ញាធរមានសមត្ថកិច្ចផង (ដូចជាប៉ូលីស មេឃុំជាដើម) នៅមិនទាន់បានយល់ច្បាស់អំពីច្បាប់នេះនៅឡើយ។

បច្ចុប្បន្ននេះ អាជ្ញាធរមានសមត្ថកិច្ចច្រើនតែព្រមានជាពាក្យសំដីដល់ជនល្មើស ឬគ្រាន់តែឲ្យជនល្មើសចុះកិច្ចសន្យាឈប់ប្រើអំពើហិង្សាតែប៉ុណ្ណោះ។ ដីកាការពារ និងសេចក្តីសំរេចរដ្ឋបាលជាឧបករណ៍ដ៏មានប្រសិទ្ធិភាពមួយក្នុងការការពារជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ។ ដូច្នេះដីការការពារនេះអាចដាក់បញ្ចូលលក្ខខណ្ឌដូចជា តម្រូវឲ្យជនល្មើសរស់នៅឆ្ងាយពីផ្ទះ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ ហើយតម្រូវឲ្យជនល្មើសនៅតែបន្តផ្គត់ផ្គង់សមាជិកទាំងអស់នៅក្នុងក្រុមគ្រួសារ។ ជនប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារគួរតែត្រូវបានឃាត់ខ្លួនភ្លាមៗ។ សេចក្តីសម្រេចរដ្ឋបាលឬ ដីកាការពារបណ្តោះអាសន្នគឺចាំបាច់ត្រូវតែចេញនឹងអាចពន្យាលើសពីកាលកំណត់ នៅគ្រប់ពេលដែលស្ត្រីមានអារម្មណ៍ភ័យខ្លាចថានឹងរងនូវអំពើហិង្សាបន្ថែមទៀតនៅថ្ងៃក្រោយ។

Strey Khmer ស្ត្រីខ្មែរ
Women transforming communities

Positive Change for Cambodia

GADC
Gender and Development for Cambodia

វិទ្យាស្ថានបើកទូលាយ
Open Institute

វិធីសាស្ត្របន្ទាប់ទៀតនោះគឺ ច្បាប់នេះមិនគួរគ្រាន់តែគ្របដណ្តប់លើគូរ (ស្វាមី ឬភរិយា) ដែលរស់នៅជាមួយជនល្មើសប៉ុណ្ណោះទេ ក៏ប៉ុន្តែគួររាប់បញ្ចូលគូរសង្សារប្រុសស្រី និង អតីតស្វាមី ឬភរិយាផងដែរ។ ជាញឹកញាប់ជនល្មើសបានតាមធ្វើបាបស្ត្រីដែលព្យាយាមបញ្ចប់ទំនាក់ទំនង និងចាកចេញពីខ្លួន ។ មានតែដីការការពារ ឬការកាត់ទោសឲ្យជាប់ពន្ធនាគារប៉ុណ្ណោះទេ ទើបអាចជួយជនរងគ្រោះបាន ។

បច្ចុប្បន្នចំពោះករណីអំពើហិង្សាក្នុងគ្រួសារ នៅមានចៅក្រម និងព្រះរាជអាជ្ញាមួយចំនួន អនុវត្តតែមាត្រាទី ២២២ នៃក្រមព្រហ្មទណ្ឌប៉ុណ្ណោះ ដែលមាត្រានេះមិនបានដាក់បញ្ចូលអំពើហិង្សា ចំពោះគូរភរិយាស្វាមីទេ នេះបង្ហាញថាមាត្រាផ្សេងទៀតដែលដាក់ទោសរយះពេលវែងជាងនេះ មិនត្រូវបានយកមកប្រើប្រាស់ទេ ពីព្រោះនៅក្នុងមាត្រាទាំងនោះមិនបានលើកឡើងជាក់លាក់ពីគូរស្វាមីភរិយាទេ។ ទាំងក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ គួរតែមានការពិនិត្យកែប្រែឡើងវិញ ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ថា រាល់បទឧក្រិដ្ឋនៅតែជាបទឧក្រិដ្ឋ បើទោះជាជនរងគ្រោះជាសាច់ញាតិរបស់ជនល្មើសក៏ដោយ។ ចំពោះករណីដែលជនរងគ្រោះត្រូវជាសាច់ញាតិនឹងជនល្មើស ការប្រព្រឹត្តនោះត្រូវនៅជាការប្រព្រឹត្តដែលមានស្ថានទម្ងន់ទោស ដែលត្រូវកាត់ទោសឲ្យជនល្មើសជាប់ពន្ធនាគាររយៈពេលវែងទៅតាមអង្គហេតុ មិនមែនបន្ថយរយៈពេលជាប់ពន្ធនាគារឲ្យកាន់តែខ្លីនោះទេ។

ជាចុងបញ្ចប់ បើទោះជាមានច្បាប់ល្អយ៉ាងណាក៏ដោយ ក៏មិនអាចការពារស្ត្រីបានដែរ លុះណាអាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីរដ្ឋាភិបាលទាំងអស់យល់ឲ្យបានច្បាស់លាស់ពីច្បាប់ និងអនុវត្តច្បាប់នេះឲ្យបានពេញលេញ នោះទើបអាចការពារស្ត្រីប្រកបដោយប្រសិទ្ធភាពទៅបាន។ យើងខ្ញុំសូមអំពាវនាវយ៉ាងទទូចដល់រដ្ឋាភិបាល សូមលោកមេត្តាផ្តល់វគ្គបណ្តុះបណ្តាលពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដល់គ្រប់អាជ្ញាធរមានសមត្ថកិច្ចទាំងថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក ប្រព័ន្ធទំនាក់ទំនងដូចខាងក្រោម៖


- លោកស្រី ជឹម ចាន់នាង: ០១២ ៦៦៨ ៨៥៣ Email: ngocedaw.pnh@gmail.com
- លោក ឆាយ គឹមស៊័រ: ០១២ ៦២៧ ៨៣៧ E-mail: com@gadc.org.kh